ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ១២៧ សសរ.កសក

# សេចក្តីសម្រេច
# ស្តីពី
# ការប្រគល់ភារកិច្ចជូនទីប្រឹក្សាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការនិងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្មចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួង ទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្មឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ ស្តីពីការដំឡើងនាយកដ្ឋានផលិតកម្មនិងបសុព្យាបាលទៅជាអគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ
- យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ: (០២៣)៧២៦ ១២៨ /៧២៦ ១២៩ ទូរសារលេខ: (៨៥៥)២៣-២១៧ ៣២០
N° 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia Phone: (023) 726 128 / 726 129, Fax: (855) 23 - 217 320

## សម្រេច

**ប្រការ ១** : ត្រូវបានប្រគល់ភារកិច្ចជូនទីប្រឹក្សាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដូចខាងក្រោម៖

១: ឯកឧត្តម **តេខ ឡៅ** ទីប្រឹក្សាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទទួលបន្ទុកលើកិច្ចការ ៖
- ពាក់ព័ន្ធនឹងគណៈកម្មការជំរុញការនាំចេញកសិផល
- នាទីផ្សព្វផ្សាយកសិកម្ម វេទិកាស្វែងយល់ពីកសិកម្ម និងទស្សនាវដ្ដីកសិកម្ម
- ចូលរួមប្រជុំ ពិភាក្សា ផ្ដល់យោបល់លើការងារផ្សេងៗទៀតតាមការចាំបាច់ដែលក្រសួងប្រគល់ជូន។

២: ឯកឧត្តម **លឹម សុគុណា** ទីប្រឹក្សាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទទួលបន្ទុកលើកិច្ចការ ៖
- ពាក់ព័ន្ធនឹងការងាររបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី
- ពាក់ព័ន្ធនឹងក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- ចូលរួមប្រជុំ ពិភាក្សា ផ្ដល់យោបល់លើការងារផ្សេងៗទៀតតាមការចាំបាច់ដែលក្រសួងប្រគល់ជូន។

៣: ឯកឧត្តម **ច័ន្ទ នរ៉ា** ទីប្រឹក្សាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទទួលបន្ទុកលើកិច្ចការ ៖
- ពាក់ព័ន្ធនឹងក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល
- ពាក់ព័ន្ធនឹងគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (វិមជ្ឈការ និងវិសហមជ្ឈការ)
- ចូលរួមប្រជុំ ពិភាក្សា ផ្ដល់យោបល់លើការងារផ្សេងៗទៀតតាមការចាំបាច់ដែលក្រសួងប្រគល់ជូន។

៤: ឯកឧត្តម **សឿន សម្បត្តិ** ទីប្រឹក្សាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទទួលបន្ទុកលើកិច្ចការ ៖
- ពាក់ព័ន្ធនឹងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- ចូលរួមប្រជុំ ពិភាក្សា ផ្ដល់យោបល់លើការងារផ្សេងៗទៀតតាមការចាំបាច់ដែលក្រសួងប្រគល់ជូន។

៥: ឯកឧត្តម **អ៊ុក ពញ្ញា** ទីប្រឹក្សាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទទួលបន្ទុកលើកិច្ចការ ៖
- តាំងពិព័រណ៍ជាតិ និងពិព័រណ៍អន្តរជាតិ
- ចូលរួមប្រជុំ ពិភាក្សា ផ្ដល់យោបល់លើការងារផ្សេងៗទៀតតាមការចាំបាច់ដែលក្រសួងប្រគល់ជូន។

៦: ឯកឧត្តម **សុខ ស៊ីឡា** ទីប្រឹក្សាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទទួលបន្ទុកលើកិច្ចការ ៖
- ពាក់ព័ន្ធនឹងក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ(CARD) គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា(CNMC) គណៈកម្មការទន្លេមេគង្គ(MRC) និងអង្គការពាណិជ្ជកម្មពិភពលោក(WH
- ក្នុងក្របខ័ណ្ឌក្រុមការងារបច្ចេកទេសកសិកម្មនិងទឹក(TWGA-W)
- ចូលរួមប្រជុំ ពិភាក្សា ផ្ដល់យោបល់លើការងារផ្សេងៗទៀតតាមការចាំបាច់ដែលក្រសួងប្រគល់ជូន។

៧: ឯកឧត្តម **អ៊ាង សុផល្លា** ទីប្រឹក្សាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទទួលបន្ទុកលើកិច្ចការ ៖
- ពាក់ព័ន្ធនឹងគោលនយោបាយអភិវឌ្ឍន៍ប្រជាជន និងសង្គមកិច្ចជាមួយក្រសួង ស្ថាប័នផ្សេងៗ
- ចូលរួមប្រជុំ ពិភាក្សា ផ្ដល់យោបល់លើការងារផ្សេងៗទៀតតាមការចាំបាច់ដែលក្រសួងប្រគល់ជូន។

៨: ឯកឧត្តម **សៅ សំបូរ** ទីប្រឹក្សាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទទួលបន្ទុកលើកិច្ចការ ៖
- គណៈកម្មាធិការជាតិអភិនិយោគរបស់រដ្ឋលើសហគ្រាសចម្ការកៅស៊ូ ក្រុមហ៊ុនសម្ភារកសិកម្ម និងក្រុមហ៊ុនជលផល
- ចូលរួមប្រជុំ ពិភាក្សា ផ្ដល់យោបល់លើការងារផ្សេងៗទៀតតាមការចាំបាច់ដែលក្រសួងប្រគល់ជូន។

៩: លោកជំទាវ **អ៊ូ ស៊ីរីនា** ទីប្រឹក្សាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទទួលបន្ទុកលើកិច្ចការ ៖
- ពាក់ព័ន្ធនឹងគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ពាក់ព័ន្ធនឹងគណៈកម្មាធិការជាតិ ដើម្បីទប់ស្កាត់ លុបបំបាត់ និងបង្ក្រាបការកាប់រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធដីព្រៃឈើ ដើម្បីវាតយកដីធ្វើកម្មសិទ្ធិ និងការងារអនុវត្តសន្ធិសញ្ញាប្រយុទ្ធប្រឆាំងនឹងភាពរហោស្ថានរបស់អង្គការសហប្រជាជាតិ(UNCCD)

- ចូលរួមប្រជុំ ពិភាក្សា ផ្តល់យោបល់លើការងារផ្សេងៗទៀតតាមការចាំបាច់ដែលក្រសួងប្រគល់ជូន។

១០: លោកជំទាវ **ឆ្លង ហេង** ទីប្រឹក្សាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទទួលបន្ទុកលើកិច្ចការ ៖

- ពាក់ព័ន្ធនឹងការងារណសិរ្ស សាមគ្គី-អភិវឌ្ឍន៍មាតុភូមិកម្ពុជា និងគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិនិងអន្តរជាតិ
- ពាក់ព័ន្ធការងារយេនឌ័រ
- ចូលរួមប្រជុំ ពិភាក្សា ផ្តល់យោបល់លើការងារផ្សេងៗទៀតតាមការចាំបាច់ដែលក្រសួងប្រគល់ជូន។

១១: ឯកឧត្តម **ម៉ម ម៉ារ៉ាឌី** ទីប្រឹក្សាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទទួលបន្ទុកលើកិច្ចការ ៖

- ពាក់ព័ន្ធនឹងការអនុវត្តផែនការសកម្មភាពស្តីពីយុទ្ធសាស្រ្តនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចបួនប្រទេស កម្ពុជា ឡាវ វៀតណាម និងថៃ
- ចូលរួមប្រជុំ ពិភាក្សា ផ្តល់យោបល់លើការងារផ្សេងៗទៀតតាមការចាំបាច់ដែលក្រសួងប្រគល់ជូន។

១២: ឯកឧត្តម **មាស គឹមសុវ៉ារ៉ូ** ទីប្រឹក្សាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទទួលបន្ទុកលើកិច្ចការ ៖

- ពាក់ព័ន្ធនឹងគម្រោងកម្មវិធីឡជីវៈឧស្ម័នជាតិ (NBP)
- ពាក់ព័ន្ធនឹងវិស័យផលិតកម្មនិងបសុព្យាបាល
- ចូលរួមប្រជុំ ពិភាក្សា ផ្តល់យោបល់លើការងារផ្សេងៗទៀតតាមការចាំបាច់ដែលក្រសួងប្រគល់ជូន។

១៣: ឯកឧត្តម **ថៃ ឌុទ្ធី** ទីប្រឹក្សាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទទួលបន្ទុកលើកិច្ចការ ៖

- ពាក់ព័ន្ធនឹងលិខិតបទដ្ឋានច្បាប់ និងការប្រព្រឹត្តទៅនៃអង្គភាពក្រោមឱវាទក្រសួង
- ចូលរួមប្រជុំ ពិភាក្សា ផ្តល់យោបល់លើការងារផ្សេងៗទៀតតាមការចាំបាច់ដែលក្រសួងប្រគល់ជូន។

១៤: ឯកឧត្តម **សៀក ឡេង** ទីប្រឹក្សាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទទួលបន្ទុកលើកិច្ចការ ៖

- ពាក់ព័ន្ធនឹងគណៈកម្មាធិការកំណត់ផ្ទៃទីតាំងបឹងបួរ និងគណៈកម្មាធិការដឹកនាំការងារដើម្បីអភិវឌ្ឍន៍ផ្នែកឯកជន
- ពាក់ព័ន្ធនឹងវិស័យជលផល
- ចូលរួមប្រជុំ ពិភាក្សា ផ្តល់យោបល់លើការងារផ្សេងៗទៀតតាមការចាំបាច់ដែលក្រសួងប្រគល់ជូន។

**ប្រការ ២** : រាល់ការចូលរួមក្នុងកិច្ចប្រជុំ ឬក្នុងវេទិកានានា ត្រូវធ្វើរបាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**ប្រការ ៣** : ឯកឧត្តម លោកជំទាវរដ្ឋលេខាធិការ ឯកឧត្តម លោកជំទាវអនុរដ្ឋលេខាធិការ នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត និងសាមីជនត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ២០១៧

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

វេង សាខុន

**កន្លែងទទួល** :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- ឯកសារ កាលប្បវត្តិ